# សេចក្តីជូនដំណឹងអំពីសវនាការសាធារណៈ
## សាលាក្រុងឡុងប៊ិច

LONG BEACH Utilities Water · Gas · Sewer

## សំណើដំឡើងថ្លៃទឹកស្អាត និងទឹកស្អុយ

នៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ អ្នកបោះឆ្នោះនៅរដ្ឋកាលីហ្វ័រញ៉ា បានឯកភាពសំណើលេខ ២១៨ ដោយធ្វើវិសោធនកម្មលើធម្មនុញ្ញរបស់រដ្ឋកាលីហ្វ័រញ៉ា ពាក់ព័ន្ធនឹងរដ្ឋាភិបាលមូលដ្ឋាន សោហ៊ុយ និងការយកថ្លៃផ្សេងៗ រួមទាំងថ្លៃប្រើប្រាស់សេវាទឹកស្អាត និងទឹកស្អុយ។ អនុលោមតាមសំណើ ២១៨ នេះ នាយកដ្ឋានធនធានទឹកក្រុងឡុងប៊ិច នឹងរៀបចំសវនាការសាធារណៈមួយ នៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២៤ ដើម្បីស្តាប់មតិតវ៉ារបស់សាធារណជន អំពីសំណើសុំដំឡើងថ្លៃទឹកស្អាត និងទឹកស្អុយរបស់សាលាក្រុងឡុងប៊ិច។ បើសំណើនេះត្រូវបានអនុម័ត ការដំឡើងថ្លៃនេះ នឹងចូលជាធរមានចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០២៤។ ម្ចាស់គណនីទឹកស្អាត និង/ឬទឹកស្អុយក្រុងឡុងប៊ិច អាចតវ៉ាជំទាស់នឹងសំណើសុំដំឡើងថ្លៃនេះ ដោយសរសេរជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។ ដើម្បីយកមកពិចារណាបាន រាល់សារតវ៉ាត្រូវដាក់ឲ្យបានមុនសវនាការសាធារណៈបិទបញ្ចប់។

| សារតវ៉ាជាលាយលក្ខណ៍អក្សរ ត្រូវដាក់ឲ្យបានត្រឹមថ្ងៃធ្វើសវនាការសាធារណៈ និងផ្ញើតាមសំបុត្រ ឬអ៊ីម៉េលទៅ៖ | ថ្ងៃបើកសវនាការសាធារណៈ: ថ្ងៃ ចន្ទ ទី ១៩ ខែ សីហា ឆ្នាំ ២០២៤ នៅម៉ោង 7:00 ល្ងាច |
|---|---|
| Long Beach Board of Utilities Commissioners<br>Attn: Executive Assistant to the Board<br>1800 East Wardlow Road<br>Long Beach, CA 90807<br>Email: Commission@lbutilities.org | Long Beach Utilities Building<br>1800 East Wardlow Road<br>Long Beach, CA 90807 |

### តើហេតុអ្វីបានជាខ្ញុំទទួលបានសេចក្តីជូនដំណឹងនេះ?

សំណើលេខ ២១៨ របស់រដ្ឋកាលីហ្វ័រញ៉ា (California Proposition 218) ចែងអំពីដំណើរការដែលសាលាក្រុងអាចកំណត់ ឬដំឡើងថ្លៃសេវាណាមួយបាន។ "ថ្លៃសេវាសម្រាប់អចលនទ្រព្យ" ជាក់លាក់គឺរួមមានថ្លៃប្រើប្រាស់ទឹកស្អាត និងទឹកស្អុយ ដែលត្រូវជូនដំណឹងដល់សាធារណជន អំពីសវនាការសាធារណៈ និងអំពីដំណើរការតវ៉ាជំទាស់របស់មតិភាគច្រើន ទៅនឹងការឡើងថ្លៃនេះ។ សេចក្តីជូនដំណឹងនេះ គឺជាផ្នែកមួយនៃដំណើរការនេះឯង។ ដោយសារបងប្អូនជាម្ចាស់គណនីប្រើប្រាស់សេវាទឹកស្អាត និងទឹកស្អុយ ដែលនឹងត្រូវឡើងថ្លៃនេះ បងប្អូនត្រូវទទួលបានសេចក្តីជូនដំណឹងនេះ ដោយមិនឲ្យតិចជាង ៤៥ ថ្ងៃ នៅមុនថ្ងៃបើកសវនាការសាធារណៈ ដែលគ្រោងបើកនៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២៤ នោះឡើយ។ ក្នុងនាមជាម្ចាស់គណនី បងប្អូនមានសិទ្ធិតវ៉ាជំទាស់ទៅនឹងការដំឡើងថ្លៃនេះ។

# សេចក្តីជូនដំណឹងអំពីសវនាការសាធារណៈ
## សាលាក្រុងឡុងប៊ិច

LONG BEACH Utilities
Water · Gas · Sewer

រាល់ម្ចាស់គណនីដែលមានចុះបញ្ជី និងសាធារណជនទូទៅ គឺត្រូវបានអញ្ជើញឲ្យចូលរួមក្នុងសវនាការសាធារណៈនេះ។ ក្នុងសវនាការនេះ ប្រធានក្រុមប្រឹក្សាភិបាលនៃនាយកដ្ឋានធនធានទឹក នឹងស្តាប់ ហើយពិចារណារាល់សំណើ សំណូមពរ និងការតវ៉ាជំទាស់ទៅនឹងការឡើងថ្លៃនេះ។ នៅពេលបិទបញ្ចប់សវនាការនេះ ក្រុមប្រឹក្សាភិបាលនឹងអនុម័តតម្លៃថ្មី បើសំណើដំឡើងថ្លៃនេះ មិនមាន"ការជំទាស់ភាគច្រើនលើសលុប"ពីម្ចាស់គណនី។

### សំណើដំឡើងថ្លៃទឹកស្អាត និងទឹកស្អុយ

ប្រធានក្រុមប្រឹក្សាភិបាលរបស់នាយកដ្ឋានធនធានទឹកក្រុងឡុងប៊ិច បានឯកភាពដំឡើងថ្លៃ ១១ ភាគរយ លើសេវាប្រើប្រាស់ទឹកស្អាត ដែលអតិថិជនប្រើប្រាស់សេវានេះនៅទីក្រុងឡុងប៊ិចទាំងអស់ នឹងត្រូវបង់ ហើយដំឡើងថ្លៃ ៨ ភាគរយលើសេវាទឹកស្អុយ។ ប៉ុន្តែថ្លៃដំឡើងថ្មីនេះ នឹងអនុវត្តបាន តែក្នុងករណីមានការរៀបចំសវនាការសាធារណៈមួយ និងត្រូវឯកភាពពីក្រុមប្រឹក្សាក្រុងឡុងប៊ិចសិន។ បើសំណើនេះត្រូវបានឯកភាព ថ្លៃដែលឡើងនេះនឹងត្រូវចាប់អនុវត្តពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០២៤។ តារាងលម្អិតអំពីសំណើដំឡើងថ្លៃសេវាទាំងពីរនេះ មានផ្តល់ជូននៅចុងសេចក្តីជូនដំណឹងនេះ។

### តើវិក្កយបត្រទឹករបស់ខ្ញុំនឹងត្រូវគណនាយ៉ាងដូចម្តេច?

រាល់វិក្កយបត្ររបស់អតិថិជននីមួយៗ គឺមានថ្លៃសេវាដែលបែងចែកចេញជាពីរដាច់ពីគ្នា៖

(i) ថ្លៃសេវាប្រចាំថ្ងៃ ដោយផ្អែកលើកម្រិតនាឡិកាប្រើប្រាស់របស់អតិថិជន និងចំនួនថ្ងៃដែលបានប្រើប្រាស់វា។

(ii) ការគិតថ្លៃទៅតាមទំហំនៃការប្រើប្រាស់ គឺត្រូវគិតតាមបរិមាណទឹកដែលអតិថិជនប្រើប្រាស់ សម្រាប់ក្នុងមួយវិក្កយបត្រ។

### ផលប៉ះពាល់លើវិក្កយបត្របង់ថ្លៃសេវាទឹកប្រចាំខែ

| សេវា | បច្ចុប្បន្ន | ថ្លៃដំឡើង | សរុប |
|---|---|---|---|
| ទឹកស្អាត | $56.79 | $6.25 | $63.04 |
| ទឹកស្អុយ | $11.37 | $0.91 | $12.28 |

*កំណត់ចំណាំ៖ ជាឧទាហរណ៍ តារាងនេះបង្ហាញអំពីវិក្កយបត្រមធ្យមប្រចាំខែ សម្រាប់ផ្ទះមួយគ្រួសារ គិតជាឯកត្តាសន្មត់ 9 billing units ។ ក្នុងមួយ billing unit គឺស្មើនឹង 748 gallons ។*

សម្រាប់ព័ត៌មានបន្ថែមអំពីការគិតលុយក្នុងវិក្កយបត្ររបស់បងប្អូន និងអំពីអត្រាថ្លៃដំឡើងនេះ សូមចូលមើល៖

LBUtilities.org/rates។

## ហេតុអ្វីបានជាថ្លៃទឹកចាប់ផ្តើមឡើងជាងមុន?

ប្រាក់ចំណូលដែលបានពីការបង់ថ្លៃទឹកនេះ គឺត្រូវយកមកប្រើប្រាស់សម្រាប់ដំណើរការ ការថែទាំ ជួសជុល និងផ្លាស់ប្តូរគ្រឿងបន្លាស់ប្រព័ន្ធទឹករបស់ក្រុងឡុងប៊ិច។ កាលពីក្នុងកិច្ចប្រជុំអំពីថវិកាជាសាធារណៈ និងថ្លៃសេវានេះ ចំនួនបីលើកកាលពីខែឧសភា និង មិថុនា ក្រុមប្រឹក្សាភិបាលធនធានទឹកបានកំណត់ និងផ្តល់អាទិភាពលើការវិនិយោគលើធនធានទឹកក្រោមដី នៅក្នុងមូលដ្ឋានរបស់យើង ដែលរួមមានជីកអណ្តូងទឹកពីក្រោមដីថ្មីៗ និងដំឡើងបំពង់បញ្ជូនទឹកប្រវែងជាង ១,៨០០ ម៉ែយ៍ និងរៀបចំអាងស្តុកទឹកផង។ គួបផ្សំនឹងកិច្ចខំប្រឹងប្រែងយ៉ាងខ្លាំងក្លារបស់អតិថិជនយើង ដែលលោកខំសន្សំសំចៃទឹក មានន័យថាការវិនិយោគលើការកែលម្អប្រព័ន្ធទឹករបស់យើង នឹងធានានិរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាតសម្រាប់បរិភោគ សម្រាប់សហគមន៍យើង និងជួយសន្សំសំចៃសម្រាប់អតិថិជនយើងដែរ ដ្បិតអ្នកប្រើប្រាស់ទឹកនឹងកាត់បន្ថយការពឹងផ្អែកលើធនធានទឹកដែលនាំចូល និងមានតម្លៃថ្លៃខ្លាំង។ ដើម្បីមើលបទបង្ហាញ និងសារជាសំឡេងពីសិក្ខាសាលាស្តីពីថវិកា ដែលធ្វើនៅថ្ងៃទី ០២ ខែ ឧសភា និង ១៦ ខែ ឧសភា និង ថ្ងៃទី ០៦ ខែ មិថុនា សូមបងប្អូនចូលមើល៖ LBUtilities.org/budget។

នាយកដ្ឋានធនធានទឹកក្រុងឡុងប៊ិច នៅតែបន្តកាត់បន្ថយថ្លៃសេវាប្រើប្រាស់ទឹកស្អាត និងទឹកស្អុយ តាមដែលអាចធ្វើទៅបាន ដើម្បីជួយកាត់បន្ថយការដំឡើងថ្លៃប្រើប្រាស់ទឹក។ នាយកដ្ឋានយល់ថាបងប្អូនប្រជាពលរដ្ឋយើងជាច្រើន និងអាជីវកម្មផង អាចរងផលប៉ះពាល់ដោយសារបញ្ហាសេដ្ឋកិច្ចក្នុងពេលបច្ចុប្បន្ននេះ។ សំណើសុំដំឡើងថ្លៃសេវាទឹកនេះ គឺជាការដំឡើងថ្លៃដ៏តិចតួចបំផុតតាមដែលអាចធ្វើទៅបាន ដែលការធ្វើដូច្នេះគឺដើម្បីឲ្យនាយកដ្ឋានធនធានទឹក នៅតែបន្តមានលទ្ធភាពវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរបស់យើង និងបន្តផ្តល់ទឹកស្អាតសម្រាប់បរិភោគ ដែលមានគុណភាពល្អ និងសុវត្ថិភាពសម្រាប់សហគមន៍យើង។ អត្រាថ្លៃសេវាទឹករបស់ទីក្រុងឡុងប៊ិច នៅតែទាបជាងបណ្តាទីក្រុងធំៗដទៃទៀតនៅរដ្ឋកាលីហ្វ័រញ៉ាយើង រួមទាំងទីក្រុង Los Angeles, San Diego, San Francisco, San Jose និង Oakland ផង។

## ចុះហេតុដូចម្តេចបានជាទឹកស្អុយឡើងថ្លៃដែរ?

មិនខុសពីប្រព័ន្ធទឹកស្អាត នាយកដ្ឋានធនធានទឹកក្រុងឡុងប៊ិច មានប្រព័ន្ធលូទឹកស្អុយដែលចាស់ជរាណាស់ហើយ។ កន្លងមកតាមបទពិសោធន៍ គឺដើម្បីថែទាំប្រព័ន្ធនេះឲ្យនៅល្អ គឺយើងត្រូវសម្រុកថែទាំ និងលាងសម្អាតវា។ ដើម្បីការពារសុខភាពសាធារណៈ ការពារបរិស្ថានរបស់យើង និងរក្សាប្រព័ន្ធទឹកស្អុយឲ្យនៅល្អជាទីទុកចិត្ត នាយកដ្ឋានធនធានទឹកក្រុងឡុងប៊ិច បានកំណត់រកឃើញបច្ចេកវិទ្យាថ្មីជាច្រើន និងឧបករណ៍ ដើម្បីដំឡើងនៅតាមតំបន់ជាក់លាក់មួយចំនួន ក្នុងប្រព័ន្ធលូទឹកស្អុយរបស់ក្រុងឡុងប៊ិច ដើម្បីបង្ការការលេចធ្លាយទឹកស្អុយ។

ដោយប្រើទិន្នន័យពីប្រព័ន្ធកាម៉េចាប់រូបវីដេអូ CCTV footage នាយកដ្ឋានយើងខ្ញុំបានកំណត់ឃើញបញ្ហាប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធទឹកស្អុយ ដែលត្រូវការស្តារឡើងវិញ។ ច្បាប់ និងវិធានថ្មីៗបានតម្រូវឲ្យបង្កើនការថែទាំឲ្យបានញឹកញាប់ និងកែលម្អប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធទឹកស្អុយនេះ។

**ដំណើរការ "តវ៉ាជំទាស់ដោយមតិភាគច្រើនលើសលុប"**

រាល់ការតវ៉ាជំទាស់ គឺត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬធ្វើដោយផ្ទាល់មាត់ ក្នុងអំឡុងពេលសវនាការ ដើម្បីរាប់ចូលទៅក្នុងការតវ៉ានៃមតិភាគច្រើនលើសលុបនោះ។ បងប្អូនអាចដាក់សារតវ៉ាជំទាស់នេះជាលាយលក្ខណ៍អក្សរ តាមសំបុត្រធម្មតា ឬតាមអ៊ីម៉េល ឬយកមកដល់ផ្ទាល់ដៃ នៅក្នុងពេលសវនាការសាធារណៈនោះក៏បាន។ រាល់លិខិតតវ៉ាជំទាស់ដែលផ្ញើតាមសំបុត្រ ឬអ៊ីម៉េល ត្រូវធ្វើយ៉ាងណាឲ្យបានដល់ដៃជំនួយការក្រុមប្រឹក្សាភិបាលនៃគណៈកម្មការធនធានទឹកក្រុងឡុងប៊ិច (មិនមែនកាលបរិច្ឆេទដែលបោះត្រាលើលិខិតផ្ញើចេញ) ឲ្យបានត្រឹមម៉ោងបិទបញ្ចប់សវនាការសាធារណៈ នៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២៤។ បើបងប្អូនមិនបានត្រៀមលិខិតតវ៉ាជំទាស់ជាលាយលក្ខណ៍អក្សរទុកជាមុន បងប្អូនអាចដាក់សារតវ៉ានេះដោយផ្ទាល់មាត់ក៏បាន នៅក្នុងសវនាការសាធារណៈនោះ។

បងប្អូនត្រូវចុះហត្ថលេខាលើលិខិតតវ៉ានោះ ឬបញ្ជាក់ដោយផ្ទាល់មាត់ផ្ទាល់ និងសូមដាក់ឈ្មោះរបស់បងប្អូន និងអាសយដ្ឋានលំនៅឋានផង។ បើម្ចាស់គណនីទឹកដាក់ពាក្យតវ៉ា គណនីនោះត្រូវចាត់ទុកថាកំពុងស្ថិតក្នុងស្ថានភាពតវ៉ាជំទាស់ទៅនឹងសំណើសុំដំឡើងថ្លៃទឹក។ ក្នុងគណនីប្រើប្រាស់ទឹកមួយ មានសិទ្ធិតវ៉ាមួយសំឡេង ដែលសំឡេងនេះនឹងបញ្ចូលទៅក្នុងសំឡេងតវ៉ាមតិភាគច្រើនលើសលុបនោះ។

ជំនួយការនៃនាយកដ្ឋានធនធានទឹក នឹងបង្ហាញសារតវ៉ានោះភ្លាមៗ នៅក្រោយពេលបិទបញ្ចប់សវនាការសាធារណៈ និងរាយការណ៍លទ្ធផលនេះដោយផ្ទាល់ទៅកាន់គណៈក្រុមប្រឹក្សាភិបាលធនធានទឹកក្រុងឡុងប៊ិច។ ក្រុមប្រឹក្សាភិបាលនេះអាចអនុម័តតម្លៃថ្មី បើការតវ៉ាជំទាស់ទៅនឹងសំណើសុំដំឡើងថ្លៃទឹកនេះ មិនបានគ្រប់ចំនួនមតិតវ៉ាជំទាស់ភាគច្រើនលើសលុប នៃម្ចាស់គណនីប្រើប្រាស់ទឹក។

- បើបងប្អូនមិនចង់តវ៉ាជំទាស់ទៅនឹងការដំឡើងថ្លៃទឹកនេះ បងប្អូនមិនចាំបាច់ធ្វើអ្វីនោះទេ។
- បើបងប្អូនចង់តវ៉ាជំទាស់ទៅនឹងការដំឡើងថ្លៃទឹកនេះ បងប្អូនត្រូវតែបង្ហាញការតវ៉ានោះដូចខាងលើ។

ដើម្បីអានឯកសារបកប្រែនៃសេចក្តីជូនដំណឹងអំពីសវនាការសាធារណៈនេះ ជាភាសាអេស្ប៉ាញ ខ្មែរ ឬតាហ្គាឡុក សូមចូលមើល៖ LBUtilities.org/budget ឬទូរស័ព្ទ (562) 570-2300 ទៅស្នើសុំឲ្យគេផ្ញើមួយច្បាប់ជូនបងប្អូន។ ដើម្បីស្នើសុំការបកប្រែផ្ទាល់មាត់ នៅក្នុងសវនាការសាធារណៈនោះ សូមបងប្អូនអ៊ីម៉េលទៅ៖ commission@lbutilities.org ឲ្យបានត្រឹមថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២៤ ត្រឹមម៉ោង ៥ ល្ងាច។

# សេចក្តីជូនដំណឹងអំពីសវនាការសាធារណៈ

## សាលាក្រុងឡុងប៊ិច

La Junta de Comisionados de Servicios Públicos de Long Beach ha aprobado un aumento del 11 por ciento en todas las tarifas de agua que pagarán todos los clientes de agua del Departamento de Servicios Públicos de Long Beach y un aumento del 8 por ciento en todas las tarifas de alcantarillado que pagarán todos los clientes de alcantarillado de Long Beach Utilities, sujeto a una audiencia pública y la aprobación del Ayuntamiento. Si se aprueba, el aumento de las tarifas de agua y alcantarillado entrará en vigor el 1 de octubre de 2024.

Para leer una copia traducida de este Aviso de audiencia pública en español, jemer o tagalo, visite LBUtilities.org/budget o llame al (562) 570-2300 para que le envíen una. Para solicitar interpretación de idiomas en la audiencia pública, envíe un correo electrónico a Commission@lbutilities.org antes del 5 de agosto de 2024 a las 5:00 p. m.

ប្រធានក្រុមប្រឹក្សាភិបាលរបស់នាយកដ្ឋានធនធានទឹកក្រុងឡុងប៊ិច បានឯកភាពដំឡើងថ្លៃ ១១ ភាគរយ លើសេវាប្រើប្រាស់ទឹកស្អាត ដែលអតិថិជនប្រើប្រាស់សេវានេះនៅទីក្រុងឡុងប៊ិចទាំងអស់ នឹងត្រូវបង់ ហើយដំឡើងថ្លៃ ៨ ភាគរយលើសេវាទឹកស្អុយ។ ប៉ុន្តែថ្លៃដំឡើងថ្មីនេះ នឹងអនុវត្តបាន តែក្នុងករណីមានការរៀបចំសវនាការសាធារណៈមួយ និងត្រូវឯកភាពពីក្រុមប្រឹក្សាក្រុងឡុងប៊ិចសិន។ បើសំណើនេះត្រូវបានឯកភាព ថ្លៃដែលឡើងនេះនឹងត្រូវចាប់អនុវត្តពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០២៤។

ដើម្បីអានឯកសារបកប្រែនៃសេចក្តីជូនដំណឹងអំពីសវនាការសាធារណៈនេះ ជាភាសាអេស្ប៉ាញ ខ្មែរ ឬតាហ្គាឡុក សូមចូលមើលៈ LBUtilities.org/budget ឬទូរស័ព្ទ (562) 570-2300 ទៅស្នើសុំឲ្យគេផ្ញើមួយច្បាប់ជូនបងប្អូន។ ដើម្បីស្នើសុំការបកប្រែផ្ទាល់មាត់ នៅក្នុងសវនាការសាធារណៈនោះ សូមបងប្អូនអ៊ីម៉េលទៅៈ commission@lbutilities.org ឲ្យបានត្រឹមថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២៤ ត្រឹមម៉ោង ៥ ល្ងាច។

Inaprubahan ng Long Beach Board of Utilities Commissioners ang 11 porsiyentong pagtaas sa lahat ng mga rate ng tubig na babayaran ng lahat ng mga customer ng tubig ng Long Beach Utilities Department at isang 8 porsiyentong pagtaas sa lahat ng mga rate ng sewer na babayaran ng lahat ng customer ng Long Beach Utilities sewer, na napapailalim sa isang pampublikong pagdinig at pag-apruba ng Konseho ng Lungsod. Kung maaprubahan, ang pagtaas sa mga rate ng tubig at imburnal ay magkakabisa sa Oktubre 1, 2024.
Upang basahin ang isang isinaling kopya ng Paunawa sa Pampublikong Pagdinig na ito sa Espanyol, Khmer o Tagalog, mangyaring bisitahin ang LBUtilities.org/budget o tumawag sa (562) 570-2300 upang maipadala sa iyo ang isa. Upang humiling ng interpretasyon ng wika sa pampublikong pagdinig, mangyaring mag-email sa commission@lbutilities.org bago ang Agosto 5, 2024, bago ang 5:00 p.m.